**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

**Ministry of Environment**

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ៧ ឆ្នាំ២០ ១០

លេខៈ ១៨៦/ប.ក ប.ស្ថ

## ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "បឹងទទឹល" ភូមិកូនក្អែក ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ក្នុងដែនជម្រកសត្វព្រៃបឹងពែរ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ-អភិរក្សធម្មជាតិ របស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

- បានឃើញលិខិតស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "បឹងទទឹល" ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧។

-តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន។

## សំរេច

**ប្រការ ១ :** រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **"បឹងទទឹល"** ដែលស្ថិតនៅក្នុងភូមិកូនក្អែក ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នៃដែនជម្រកសត្វព្រៃបឹងពែរ។

**ប្រការ ២ :** សហគមន៍តំបន់ការពារធម្មជាតិ " **បឹងខ្ទីល** " ក្នុងដែនជម្រកសត្វព្រៃបឹងពែរ មានផ្ទៃដីទំហំ **២៥៨៧ហិចតា** បានកំណត់ទីតាំងព្រំប្រទល់ក្នុងផែនទី ដែលមានអាប់ស៊ីស និងកូអ័រដោនេ ដូចខាងក្រោម :

| ចំណុច | អាប់ស៊ីស X | កូអ័រដោនេ Y | ចំណុច | អាប់ស៊ីស X | កូអ័រដោនេ Y |
|---|---|---|---|---|---|
| A | 504485 | 1440467 | F | 509963 | 1441789 |
| B | 505817 | 1437781 | G | 509690 | 1441528 |
| C | 509683 | 1437673 | H | 508600 | 1441517 |
| D | 513003 | 1437592 | I | 507330 | 1441760 |
| E | 512312 | 1440298 | J | 506532 | 1440706 |

**ប្រការ ៣ :** ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ " **បឹងខ្ទីល** " នៃដែនជម្រកសត្វព្រៃបឹងពែរ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងផែនការគ្រប់គ្រង ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានពាក់ព័ន្ធ កម្រងតំបន់ការពារធម្មជាតិស្ទឹងសែន មន្ទីរបរិស្ថានខេត្តកំពង់ធំ ដែនជម្រកសត្វព្រៃបឹងពែរ និងសហគមន៍តំបន់ការពារធម្មជាតិ " **បឹងខ្ទីល** " នៃដែនជម្រកសត្វព្រៃបឹងពែរ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាទៅ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា

<u>ចម្លងជូន:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សាលាខេត្តកំពង់ធំ
- ឯកសារ-កាលប្បវត្តិ